# លំនៅដ្ឋានស្មើភាពគ្នាសម្រាប់បុគ្គល ដែលមានបញ្ហាសុខភាពផ្លូវចិត្ត ពិការភាពបញ្ញា និងការលូតលាស់មិនប្រក្រតី




ចូលមើលនៅ **www.hud.gov/fairhousing**
ឬទូរសព្ទមកលេខទូរសព្ទ
ទាន់ហេតុការណ៍សម្រាប់ការរើសអើង
ថ្នាក់ជាតិតាមលេខ **1-800-669-9777** ឬ
**1-800-877-8339** (លេខបញ្ជូនបន្តទៅសហព័ន្ធ)

Khmer



# លំនៅដ្ឋានស្មើភាពគ្នាសម្រាប់បុគ្គលដែលមានបញ្ហាសុខភាពផ្លូវចិត្ត ពិការភាពបញ្ញា ឬការលូតលាស់មិនប្រក្រតី

**ច្បាប់លំនៅដ្ឋានស្មើភាពគ្នា** ហាមឃាត់ចំពោះការរើសអើងប្រឆាំងនឹងជនពិការក្នុងលំនៅដ្ឋាន រួមបញ្ចូលទាំងបុគ្គលដែលមានបញ្ហាសុខភាពផ្លូវចិត្ត ពិការភាពបញ្ញា ឬការលូតលាស់មិនប្រក្រតី។
ឧទាហរណ៍អំពីការរើសអើងលំនៅដ្ឋានផ្អែកទៅលើពិការភាពមានដូចជា៖

- ការបដិសេធមិនជួលលំនៅដ្ឋានឱ្យលោកអ្នកដោយសារតែពិការភាពអ្វីមួយ
- ការបដិសេធមិនផ្តល់ការទទួលយកសមរម្យ ឬការផ្លាស់ប្តូរសមរម្យ ដែលអាចត្រូវការជាចាំបាច់សម្រាប់អ្នក ឬសម្រាប់បុគ្គលម្នាក់ ដែលអ្នករស់នៅជាមួយដើម្បីឱ្យមានឱកាសដូចគ្នាក្នុងការប្រើប្រាស់ ឬទទួលបានលំនៅដ្ឋានរបស់លោកអ្នក
- ការបដិសេធមិនព្រមផ្តល់ព័ត៌មានអំពី ឬបង្ហាញលំនៅដ្ឋានដែលនៅទំនេរដល់លោកអ្នក ឬអ្នកណាម្នាក់ ដែលលោកអ្នករស់នៅជាមួយដោយសារតែពិការភាពអ្វីមួយ
- ការដាក់លក្ខខណ្ឌផ្សេងពីអ្នកដទៃពេលជួលលំនៅដ្ឋានដែលទំនេរ ដូចជាការយកថ្លៃជួលខ្ពស់ជាង ឬការយកប្រាក់កក់ធានា ឬការតម្រូវឱ្យមានឯកសារបន្ថែមដោយសារតែពិការភាពអ្វីមួយ
- ការដាក់កម្រិតដល់លោកអ្នកពីការរស់នៅក្នុងអគារជាក់លាក់មួយ ឬផ្នែកនៃលំនៅដ្ឋានមួយក្រុម ដោយសារតែពិការភាពអ្វីមួយ
- ការបណ្តេញលោកអ្នក ឬអ្នកដែលលោកអ្នករស់នៅជាមួយចេញដោយសារតែពិការភាពអ្វីមួយ
- ការឃាឃីលោកអ្នក ឬបុគ្គលដែលលោកអ្នករស់នៅជាមួយដោយសារតែពិការភាពអ្វីមួយ

**ចូលមើលនៅ https://www.hud.gov/fairhousing ដើម្បីស្វែងយល់បន្ថែមអំពីសិទ្ធិក្នុងការទទួលបានលំនៅដ្ឋានស្មើភាពគ្នារបស់លោកអ្នក។**

**តើលោកអ្នកធ្លាប់ទទួលរងការរើសអើងលំនៅដ្ឋានដែរឬទេ? ចូលមើលនៅ https://www.hud.gov/fairhousing/fileacomplaint** ឬទូរសព្ទទៅ **លេខទាន់ហេតុការណ៍របស់ HUD តាមលេខ 1-800-669-9777 (អង់គ្លេស/អេស្ប៉ាញ) ឬ 1-800-877-8339 (លេខបញ្ជូនបន្តទៅសហព័ន្ធ) ដើម្បីដាក់ពាក្យបណ្តឹង។**

EQUAL HOUSING OPPORTUNITY

**វិធានការដែលអ្នកផ្តល់សេវាលំនៅដ្ឋានចាត់ឡើងប្រឆាំងនឹងលោកអ្នក ដោយសារតែលោកអ្នកបានដាក់ពាក្យបណ្តឹងអំពីលំនៅដ្ឋានស្មើភាពគ្នាគឺជាអំពើខុសច្បាប់។**



Khmer